ការជួយកុមារតូចៗ ឲ្យកើតមានការចាប់អារម្មណ៍ក្នុងការសិក្សា

តាមរយៈការនិយាយទៅកាន់ក្មេងៗ នោះគេ នឹងរៀននិយាយបានល្អប្រសើរ ។

- និយាយអំពីពណ៌ សំឡេង និងក្លិន នៅក្នុង និងនៅជុំវិញផ្ទះរបស់អ្នក ។
- និយាយអំពីកិច្ចការប្រចាំថ្ងៃ ។ ប្រាប់ឈ្មោះ ខោអាវ ក្នុងកាលអ្នកជួយស្លៀកពាក់ឲ្យកូន ។
- សួរសំណួរកូន ។ ឲ្យគេសួរសំណួរអ្នកវិញ។
- និយាយពាក្យឲ្យពេញឃ្លា ។ ប្រើឲ្យច្រើននៅពេលនិយាយ ។
- និយាយប្រាប់រឿងផ្សេងៗ ហើយនិយាយអំពីការនោះជាមួយគេ ។ សុំឲ្យគេស្មានពីការអ្វី នឹងកើតឡើងនៅបន្ទាប់ទៀត ឬឲ្យគេសួរសំណួរអ្នក ។
- សុំកូនឲ្យប្រាប់អ្នក ពីការអ្វីដែល

ជួយក្មេងៗ ឲ្យរៀនពាក្យថ្មី ។

- ហាត់ទះដៃបញ្ជេញស្នូរជាពាក្យ ។ ចាត្តអក្សរ និងសំឡេងរបស់ពាក្យ ។
- ប្រើចំរៀង ធ្វើម្រាមដៃ ល្បែង និងពាក្យចូន (ដូចជា គុក្ខតាដើរ គេះតាស់ ឬសុខាសរសេរ ខ្ចៃខ្ចៃ) ។
- បង្ហាញក្មេងៗនូវពាក្យថ្មី ។ ពន្យល់អត្ថន័យពាក្យ ជាពាក្យដែលគេអាចយល់បាន ។

ប្រើការលេង ដើម្បីជួយក្មេងៗ ឲ្យរៀន ។

- ក្មេងៗអាចប្រើការអានអក្សរ និងការសរសេរអក្សរ នៅក្នុងកំឡុងពេលលេង ។
- ប្រើសំបុត្រឥតបានការ ដើម្បីលេងធ្វើជាប៉ូស្តសំបុត្រ ។
- ប្រើក្រដាសរសេរ ដើម្បីលេងធ្វើជាអ្នកបំពាក់ប្រុសស្រី នៅក្នុងហាងជនីយដ្ឋាន ។
- រៀបចំ "ការិយាល័យ" ជាកន្លែងលេងមួយ ជាមួយនឹងក្រដាសមិនប្រើការ និងខ្មៅដៃ ។

FIRST 5 CALIFORNIA

ល្បិចការរៀនសូត្រ តាំងពីនៅក្មេងវ័យ

ការជួយក្មេងៗឲ្យរៀនតាំងពីនៅក្មេងវ័យ

ល្បិចដើម្បីជួយក្មេងៗ ឲ្យរៀននិយាយ រៀនអាន និងរៀនសរសេរ

ដើម្បីជួយក្មេងៗឲ្យបានស្រេចចិត្ត ឲ្យចេះអាន និងសរសេរ នោះអ្នកអាច :

- សុំឲ្យកូនគូររូប ហើយឲ្យគេប្រាប់អ្នកអំពីឈ្មោះរូបនោះ ។
- បង្ហាញឲ្យផ្គូរផ្គងរូបភាព ជាមួយនឹងពាក្យបានសរសេរ ។
- ជួយកូនកាត់យកពាក្យចេញពីទស្សនាវដ្ដី ។
- លើកទឹកចិត្ដពីភាពប៉ិនប្រសប់សរសេរ សូម្បីតែការគូសលេង នៅអាយុក្មេងខ្ចីក៏ដោយ ។

ល្បិចផ្សេងៗទៀត ដើម្បីចងចាំ ។

- ផ្ដល់សេចក្ដីស្រឡាញ់ និងការយកចិត្ដទុកដាក់ដល់កូនៗ ។
- អានសៀវភៅ ច្រៀងចំរៀង និងនិយាយជាមួយកូនៗ យ៉ាងរាល់ថ្ងៃ ។
- សរសេរតាមសេចក្ដីត្រូវការរបស់កូនភ្លាម ។
- ធ្វើយសំរែកយំរបស់កូនងើត និងធ្វើយសំណួររបស់កូន ។
- ធ្វើកន្លែងលេងឲ្យមានក្ដីសុខ ។
- ផ្ដល់ពេលវេលាឲ្យកូនរត់ លោត និងរាំ ។
- ឲ្យកូនគូរគំនូរ ឬលេងជាមួយដុំឬបន្ទះដំរៀបជារូបផ្សេងៗ ។
- ផ្ដល់ឱ្យកាសឲ្យកូនៗ ដើម្បីធ្វើការអ្វីមួយដោយខ្លួនឯង ។

- វាក៏ជាការល្អដែរ ដើម្ប៉ី :
  - រៀបចំពេលវេលា ដើម្ប៉ីលេងជាមួយក្មេងៗ ផ្សេងៗទៀត ។
  - អនុញ្ញាតឲ្យកូនមានការជ្រើសរើសខ្លះ ។
  - ត្រូវមានចិត្ដសប្ប៉ុរស និងមានការថ្នាក់ថ្នម ធ្វើជាគំរូសំរាប់កូនៗ ។

សូមទូរស័ព្ទទៅបណ្ណាល័យនៅតំបន់របស់អ្នក ដើម្ប៉ីឲ្យបានពត៌មានថែមទៀត ស្ដីអំពីការអានអក្សរ និងកម្មវិធីសំរាប់ក្មេងៗ ។

©2003 First 5 California